# កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងបំពេញបន្ថែម
# រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា
# បន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ
# ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្ត
# ឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្តីពីសម្ភារៈប្រើប្រាស់ ការជួយសម្រួល និងសេវាកម្ម ឆ្នាំ២០០៦

## មាត្រា ៦ (ថ្មី)

## ជំនួយសង្គ្រោះបឋម និងសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ

១. រាជរដ្ឋាភិបាលកម្ពុជា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ត្រូវធ្វើឱ្យប្រាកដថាមានគ្រឿងបរិក្ខារវេជ្ជសាស្ត្រគ្រប់គ្រាន់នៅក្នុងអាគារ សម្រាប់ការសង្គ្រោះបឋមក្នុងករណីបន្ទាន់។

២. រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាឱ្យមានការចូលពិនិត្យ និងព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យកាល់ម៉ែត ឬមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ក្នុងរាជធានីភ្នំពេញ នៅពេលណាដែលត្រូវការ នៅក្នុងករណីសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ ដែលកើតឡើងនៅក្នុងអាគារ។ រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវធានាផងដែរថា ដោយរ៉ាប់រងការចំណាយដោយខ្លួនឯង ការដឹកជញ្ជូនចាំបាច់សម្រាប់ករណីនេះ ត្រូវធ្វើតាមការហៅទូរស័ព្ទ រៀងរាល់ថ្ងៃ និងគ្រប់ពេលវេលា និងរៀងរាល់ម៉ោង មិនថាជាថ្ងៃធ្វើការ ឬម៉ោងធ្វើការ ឬផ្សេងពីនេះនោះឡើយ។

ចុះហត្ថលេខានៅទីក្រុងភ្នំពេញ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ តំណាងរាជរដ្ឋាភិបាលកម្ពុជាដោយលោក ក្រាន់ តូនី ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតំណាងអង្គការសហប្រជាជាតិដោយលោក Knut Rosandhaug មន្ត្រីសម្របសម្រួល UNAKRT និងជាអនុប្រធានការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អនុលោមតាមការផ្លាស់ប្តូរលិខិត និងសមត្ថកិច្ចពេញលេញរៀងៗខ្លួនដែលត្រូវបានធ្វើប្រតិភូកម្ម។